# YOU CAN




# PT OUT

## KNOW YOUR RIGHTS

ឪពុកម្តាយជាច្រើនមានការព្រួយបារម្ភអំពីផលប៉ះពាល់នៃការធ្វើតេស្តកូនរបស់ខ្លួនតាមស្តង់ដារដែលកំណត់ដោយរដ្ឋ។ សមាគមគ្រូបង្រៀនរដ្ឋកាលីហ្វ័រញ៉ានឹងផ្តល់ព័ត៌មាននេះដើម្បីឱ្យឪពុកម្តាយដឹងពីសិទ្ធិរបស់ខ្លួនទាក់ទងនឹងការសម្រេចចិត្តមិនឱ្យធ្វើតេស្តកូនរបស់ខ្លួនដោយមានហានិភ័យខ្ពស់។

**តើប្រព័ន្ធ CAASPP គឺជាអ្វី?** ការវាយតម្លៃពីសមត្ថភាព និងវឌ្ឍនភាពរបស់សិស្សនៃរដ្ឋកាលី (CAASPP) គឺជាប្រព័ន្ធរបស់រដ្ឋសម្រាប់ធ្វើការវាយតម្លៃដែលបានកំណត់ និងដោយស្រេចចិត្ត។ បច្ចុប្បន្ននេះ វារួមបញ្ចូលការធ្វើតេស្តដែលបានកំណត់ចំនួនបីប្រភេទ៖ ការវាយតម្លៃតុល្យភាព និងភាពឆ្លាតវៃ ការវាយតម្លៃជំនួសរដ្ឋកាលីហ្វ័រញ៉ា និងការវាយតម្លៃវិទ្យាសាស្រ្តនៃរដ្ឋកាលីហ្វ័រញ៉ា ។ ការវាយតម្លៃតុល្យភាព និងភាពឆ្លាតវៃ គឺស្ថិតនៅក្នុងមុខវិជ្ជាភាសាអង់គ្លេស សិល្បៈ និងគណិតវិទ្យាសម្រាប់ថ្នាក់ទី 3 ដល់ទី 8 និង 11 ។ ចំពោះព័ត៌មានបន្ថែមអំពី CAASPP សូមចូលទៅកាន់គេហទំព័រ [http://www.cde.ca.gov/ta/tg/ca](http://www.cde.ca.gov/ta/tg/ca)។

**តើឪពុកម្តាយអាចសម្រេចចិត្តមិនឱ្យធ្វើតេស្តកូនរបស់ពួកគាត់ដោយរដ្ឋបានទេ?** ស្របតាមច្បាប់។ មាត្រាទី 60615 នៃច្បាប់អប់រំរបស់រដ្ឋកាលីហ្វ័រញ៉ា អនុញ្ញាតឱ្យឪពុកម្តាយ ឬអាណាព្យាបាលដាក់សំណើជាលាយលក្ខណ៍អក្សរទៅកាន់ក្រុមមន្ត្រីសាលារៀនដើម្បីដកកូនរបស់គាត់ចេញពីផ្នែកណាមួយ ឬផ្នែកទាំងអស់នៃការវាយតម្លៃដែលកំណត់ដោយរដ្ឋ។ មាត្រាទី 852 នៃជំពូកទី 5 នៃច្បាប់បទបញ្ញត្តនៃរដ្ឋកាលីហ្វ័រញ៉ា ចែងបន្ថែមទៀតថា ជារៀងរាល់ឆ្នាំឪពុកម្តាយ ឬអាណាព្យាបាលអាចដាក់សំណើជាលាយលក្ខណ៍អក្សរទៅកាន់សាលារៀនដើម្បីដកកូនរបស់ខ្លួនចេញពីផ្នែកណាមួយ ឬផ្នែកទាំងអស់នៃការវាយតម្លៃ CAASPP សម្រាប់ឆ្នាំសិក្សា។

**តើឪពុកម្តាយសម្រេចចិត្តមិនឱ្យធ្វើតេស្តកូនរបស់ខ្លួនតាមស្តង់ដារកំណត់ដោយរបៀបណា?** សូមពិនិត្យមើលព័ត៌មានជាក់លាក់ជាមួយមណ្ឌលសាលារៀនរបស់អ្នក ប៉ុន្តែជាទូទៅ ឪពុកម្តាយសរសេរសំបុត្រមួយទៅកាន់អ្នកគ្រប់គ្រង ឬនាយកសាលាដោយអនុញ្ញាតឱ្យ ពួកគាត់ដឹងថា កូនរបស់ខ្លួននឹងមិនចូលរួមក្នុងការធ្វើតេស្តជាក់លាក់ (ដាក់ឈ្មោះតេស្ត) នៅឆ្នាំនេះ ហើយស្នើសុំឱ្យសាលាធ្វើការរៀបចំសម្រាប់ផ្តល់បទពិសោធន៍នៃការសិក្សាប្រកបដោយផលិតភាពសម្រាប់កូនរបស់ពួកគាត់ក្នុងអំឡុងពេលធ្វើតេស្តនេះ។

**ការសម្រេចចិត្តមិនឱ្យធ្វើតេស្តនេះប៉ះពាល់ដល់ពិន្ទុ ឬចំណាត់ថ្នាក់របស់កូនខ្ញុំដោយរបៀបណា?** បច្ចុប្បន្ននេះពុំមានផលវិបាកណាដែលកំណត់ដោយរដ្ឋសម្រាប់សិស្សដែលមិនទទួលយកការវាយតម្លៃតុល្យភាព និងភាពឆ្លាតវៃ ឬការធ្វើតេស្តផ្សេងទៀតដែលកំណត់ដោយរដ្ឋទេ។

**ការសម្រេចចិត្តមិនឱ្យធ្វើតេស្តនេះស្របតាមច្បាប់ឬអត់?** ស្របតាមច្បាប់។ ខណៈពេលដែលមានច្បាប់សហព័ន្ធតម្រូវឱ្យរដ្ឋគ្រប់គ្រងការធ្វើតេស្តទាំងនេះយ៉ាងហោចណាស់ 95% នៃសិស្សដែលមានសិទ្ធិ ច្បាប់ស្តីពីរាល់សិស្សទាំងអស់ទទួលបានជោគជ័យ (ESSA) ទទួលស្គាល់នូវសិទ្ធិរបស់ឪពុកម្តាយក្នុងការបដិសេធការធ្វើតេស្តនៅក្នុងរដ្ឋដែលមានច្បាប់ស្តីពីការសម្រេចចិត្តមិនចូលរួម។ មាត្រាទី 60615 នៃច្បាប់អប់រំនៃរដ្ឋកាលីហ្វ័រញ៉ាអនុញ្ញាតឱ្យឪពុក ឬម្តាយឬអាណាព្យាបាលដាក់សំណើជាលាយលក្ខណ៍អក្សរទៅកាន់ក្រុមមន្ត្រីសាលារៀនដើម្បីដកកូនរបស់គាត់ចេញពីផ្នែកណាមួយ ឬផ្នែកទាំងអស់នៃការវាយតម្លៃដែលកំណត់ដោយរដ្ឋ។ មាត្រាទី 852 នៃជំពូកទី 5 នៃច្បាប់បទបញ្ញត្តនៃរដ្ឋកាលីហ្វ័រញ៉ា ចែងថា ជារៀងរាល់ឆ្នាំឪពុកម្តាយ ឬអាណាព្យាបាលអាចដាក់សំណើជាលាយលក្ខណ៍អក្សរទៅកាន់សាលារៀនដើម្បីដកកូនរបស់ខ្លួនចេញពីផ្នែកណាមួយ ឬផ្នែកទាំងអស់នៃការវាយតម្លៃ CAASPP សម្រាប់ឆ្នាំសិក្សា។

**តើកូនរបស់ខ្ញុំត្រូវធ្វើអ្វីខ្លះ ខណៈពេលដែលគេរៀបចំផ្តល់ការធ្វើតេស្ត?** សិស្សភាគច្រើនត្រូវបានផ្តល់នូវសកម្មភាពសិក្សាផ្សេងៗក្នុងអំឡុងពេលនោះ។

*លម្អិតបន្ថែមនៅទំព័រ* **2 >>>**

**ចុះបើឪពុកម្តាយដាក់សំណើដើម្បីសម្រេចចិត្តមិនចូលរួមបន្ទាប់ពីការធ្វើតេស្ត CAASPP បានចាប់ផ្តើមរួចទៅហើយ?** បើសំណើរបស់ឪពុកម្តាយត្រូវបានដាក់ជូនបន្ទាប់ពីការធ្វើតេស្តបានចាប់ផ្តើម ការធ្វើតេស្តណាមួយដែលបានបញ្ចប់នឹងត្រូវបានដាក់ពិន្ទុ ហើយលទ្ធផលនឹងត្រូវបានរាយការណ៍ទៅឱ្យឪពុកម្តាយ ឬអាណាព្យាបាល និងដាក់បញ្ចូលក្នុងសៀវភៅកំណត់ត្រារបស់សិស្ស។

**ការសម្រេចចិត្តមិនចូលរួមធ្វើឱ្យសាលា ឬមណ្ឌលរបស់ខ្ញុំចំណាយប្រាក់ដែរឬទេ?** ក្រោមការវាយតម្លៃ ESSA រដ្ឋាភិបាលសហព័ន្ធអាចមិនផ្តល់មូលនិធិទៅឱ្យរដ្ឋដែលក្រោមកម្រិត 95% និងលើកទឹកចិត្តឱ្យបណ្តារដ្ឋបង្កើតការដាក់ទណ្ឌកម្មផ្ទាល់ទៅលើមណ្ឌលក្នុងមូលដ្ឋាន។ រហូតមកដល់បច្ចុប្បន្ននេះ ថវិកាសហព័ន្ធមិនដែលត្រូវបានដកហូតពីរដ្ឋណាទេ ហើយបច្ចុប្បន្ននេះរដ្ឋកាលីហ្វ័រញ៉ាមិនដាក់ទណ្ឌកម្មលើមណ្ឌលសាលាក្នុងមូលដ្ឋាន ដែលមិនបានបំពេញតាមកម្រិតលក្ខខណ្ឌនេះឡើយ។

**តើអ្វីទៅជាគោលជំហររបស់ CTA អំពីការធ្វើតេស្ត?** CTA ជឿថា ការវាយតម្លៃគួរតែត្រូវបានធ្វើឡើងដើម្បីជូនដំណឹងអំពីការបង្រៀន និងធ្វើឱ្យប្រសើរឡើងនូវការរៀនសូត្ររបស់សិស្ស។ ការវាយតម្លៃទាំងនេះមិនមានន័យថាចាត់ចំណាត់ថ្នាក់សិស្ស ឬសាលាទេ។ ការធ្វើតេស្តរបស់រដ្ឋត្រូវទាក់ទងនឹងអាយុ និងប្រធានបទសមរម្យ ហើយត្រូវតែគ្មានការលំអៀងដោយផ្អែកលើវប្បធម៌ ជាតិសាសន៍ ភេទ សេដ្ឋកិច្ចសង្គម និងភាសា។ ការត្រិះរិះពិចារណាយ៉ាងជាក់ស្តែងទៅលើលទ្ធផល និងការកែលម្អការសិក្សារបស់របស់សិស្សតែងតែត្រូវបានធ្វើឡើងតាមរយៈវិធានការជាច្រើន និងមិនអាចផ្តោតតែលើពិន្ទុតេស្តមួយមុខទេ។

**តើខ្ញុំអាចធ្វើអ្វីខ្លះដើម្បីជួយគាំទ្រដល់ការរៀនសូត្រជាជាងការធ្វើតេស្ត?** ភ្ជាប់ទំនាក់ទំនង និងចែករំលែកទស្សនៈរបស់អ្នកជាមួយសមាគមវិស័យអប់រំរបស់អ្នកក្នុងមូលដ្ឋាន PTA ក្រុមប្រឹក្សាសាលា និងក្រុមប្រឹក្សាភិបាលសាលា។ ធ្វើការជាមួយគ្រូ និងឪពុកម្តាយសិស្សនៅក្នុងតំបន់របស់អ្នកដើម្បីរៀបចំផែនការអំពីការទទួលខុសត្រូវគ្រប់គ្រងក្នុងមណ្ឌលរបស់អ្នក (LCAP) ដោយផ្តោតទៅលើការរៀនសូត្រជាជាងការធ្វើតេស្ត។

**តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅកន្លែងណា?** ទទួលបានព័ត៌មានបន្ថែមតាមរយៈអង្គការនានាដូចជាអង្គការ CTA (www.cta.org) សមាគមវិស័យអប់រំជាតិ (www.nea.org) អង្គការ FairTest (www.fairtest.org) អង្គការ Parents Across America (www.parentsacrossamerica.org) និងអង្គការ United Opt Out (www.unitedoptout.com)។